**សូមក្រាបបង្គំទូលថ្វាយ**
**សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ**
**ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល**

**បពិត្រ សម្តេចព្រះវររាជមាតា ជាអម្ចាស់ជីវិតតម្កល់លើត្បូង ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត**

ខណៈនេះទូលព្រះបង្គំជាខ្ញុំ និងភរិយា មានក្តីក្តុកក្តួលខ្សឹកខ្សួលរំជួលចិត្តឥតឧបមា ដោយទទួលដំណឹងថា **សម្តេចរាជបុត្រីព្រះរៀម នរោត្តម បុប្ផាទេវី** ឧត្តមក្រុមប្រឹក្សាព្រះមហាក្សត្រ សមាជិកាក្រុមប្រឹក្សាធម្មនុញ្ញនិងជាអតីតរដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ទ្រង់សោយព្រះទិវង្គត នៅថ្ងៃចន្ទ ៧រោច ខែកត្តិក ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣ ត្រូវនឹងថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៩ វេលាម៉ោង ១២ : ៣០ នាទី ក្នុងព្រះជន្មាយុ៧៧ ព្រះវស្សា ដោយព្រះរោគាពាធ ។

ក្នុងឱកាសប្រកបដោយសមានទុក្ខនេះ ទូលព្រះបង្គំជាខ្ញុំនិងភរិយា សូមព្រះបរមរាជានុញ្ញាតចូលរួមរំលែកនូវព្រះមរណទុក្ខ ប្រកបដោយអនិច្ចលក្ខណធម៌ដ៏ជ្រាលជ្រៅជាមួយ**អង្គសម្តេចម៉ែ**ជាអម្ចាស់ជីវិតតម្កល់លើត្បូង ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ដោយក្តីសង្វេគ សោកស្តាយ ស្រណោះ អាឡោះអាល័យស្វែរកទីបំផុតគ្មាន ព្រោះថាការបាត់បង់ **សម្តេចរាជបុត្រីព្រះរៀម នរោត្តម បុប្ផាទេវី** គឺជាការបាត់បង់ដ៏ធំធេងបំផុតនូវតួអង្គពហុជំនាញក្នុងវិស័យវប្បធម៌ អរិយធម៌ជាតិខ្មែរ ជាដួងព្រលឹងរឹងមាំខ្លាំងក្លា ពិសេសតាំងពីសម័យសង្គមរាស្ត្រនិយមដ៏ឧត្តុង្គឧត្តមដែលមានព្រះរាជបុត្រី អង្គព្រះមហាក្សត្រដ៏ឆ្នើមព្រះនាម **នរោត្តម បុប្ផាទេវី** ដ៏ស្រស់ល្អន់ល្អៃទ្រង់ពេញព្រះហឫទ័យនឹងនាដកា ជាអង្គតួឯករបាំអប្សរា លើកតម្កើងវប្បធម៌ពណ្ណរាយជាតិថ្កើងថ្កាន ល្បីល្បាញរន្ទឺទូទាំងសកលលោក ។

ជាថ្មីម្តងទៀត ទូលព្រះបង្គំជាខ្ញុំ និងភរិយា សូមវន្ទាឧទ្ទិសដល់ដួងព្រះវិញ្ញាណក្ខន្ធ **សម្តេចរាជបុត្រីព្រះរៀម នរោត្តម បុប្ផាទេវី** ទ្រង់យាងយោនយកកំណើត បដិសន្ធិក្នុងសុគតិភពគ្រប់ៗព្រះជាតិ ពុំឃ្លាតក្លាយជាបការៈដទៃឡើយ ។

សូម **ម្លប់ម៉ែ** ជាអម្ចាស់ ជាទីគោរពសក្ការៈ ទ្រង់ស្តេចទទួលនូវអភិវន្ទនកិច្ច និងកតញ្ញូ កតវេទិតាធម៌ដ៏ខ្ពង់ខ្ពស់បំផុតពីទូលព្រះបង្គំជាខ្ញុំ និងភរិយា ។

*ថ្ងៃចន្ទ ៧រោច ខែកត្តិក ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣*
*រាជធានីភ្នំពេញ, ថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៩*
**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**